កំណាព្យ

ស្នេហា នៃ អសនី[1]

បទភុជង្គលីលា

ប្រទះពៅនៅផ្ទះញាតិ
សម្រឹង[2]ធម្មជាតិ   ល្អប្រៀបអច្ឆរា[3]។
ស្រាប់តែចិត្តខ្ញុំស្ទុះឆ្លា
ចង់បានស្នេហា   មេត្តាពីអ្នក។
ភ្នែកខ្ញុំស្វែងរកស្នេហ៍វេទន៍[4]
សុំចិត្តមួយភ្លែត   ប្រលែងនឹងនេត្រា។
ដ្បិតឆោមពៅជានរេន្ទ្រ[5]
ខ្ញុំផ្ញើនិទ្ទេស[6]   ក្ដី[7]ស្នេហ៍តាមខ្យល់។
បើជួបភ្នែកអវិចល[8]
ខ្ញុំសែនកង្វល់   ប្រជល់នឹងទុក្ខ។
ព្រោះប្រថ្នាយកមកទុក
នោបស្នេហ៍[9]ប្រគល់   ពេលមុនលាគ្នា។

ប្រើវចនានុក្រមខ្មែររបស់ពុទ្ធសាសនាបណ្ឌិត

---

[1] ស្នេហានៃអសនី : ស្នេហាដែលមានឡើងភ្លាមៗ ; coup de foudre។
[2] សម្រឹង : កិ. សម្លឹងផ្មឹងទ្រឹងរំពឹងជញ្ជឹងគិត។
[3] អច្ឆរា : អប្សរា។
[4] ស្នេហ៍វេទន៍ : ស្នេហ៍តាមអារម្មណ៍ ; télépathie amoureuse.
[5] នរេន្ទ្រ : ដូចគ្នានឹងនរិន្ទ : អ្នកដែលជាម្ចាស់នៃមនុស្ស។
[6] និទ្ទេស : (អានថា និទេស) ន. ការសម្ដែងចែកញែកសេចក្ដី។
[7] ក្ដី : ន. ដំណើរ។
[8] អវិចល : គុ. ដែលមិនកម្រើក។
[9] នោបស្នេហ៍ : ក្រពុំស្នេហ៍។

ឧប សៅ សទ្ធា   កម្រងកំណាព្យ   ៨ វិច្ឆិកា ២០២០